ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ១០៥០.១១៨.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦

**សូមគោរពជូន**

**លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**យោង ៖** - លិខិតលេខ ០១៦ សណ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ។
- ចំណារ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូនលោកជំទាវ មេត្តាជ្រាបថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ដែលមានក្រុមការងារយេនឌ័រសម្រាប់គាំទ្រការអនុវត្តជអ៣ ដំណាក់កាលទី២ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានអនុវត្តនូវសកម្មភាពដូចបានរៀបរាប់ខាងក្រោម ក្នុងការឆ្លើយតបនឹងអនុសាសន៍ទី៣ និងទី១១ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖

**<u>អនុសាសន៍ទី៣</u>**

១. **ការពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សាជាស្ត្រីនៅថ្នាក់ ខេត្ត ក្រុង ស្រុក៖** សមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ជាស្ត្រីចំនួន ៤២២រូប បានចូលរួមសិក្ខាសាលាជាស៊េរីចំនួន៣លើក ក្នុងគោលបំណងដើម្បី (១) ពង្រឹងការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា (២) ការចែករំលែកបទពិសោធន៍ ជំនាញ ចំណេះដឹងក្នុងការបំពេញការងាររវាងក្រុមប្រឹក្សាចាស់ និងក្រុមប្រឹក្សាថ្មី (៣)បង្កើនសមត្ថភាពបន្ថែមទៀតលើការអនុវត្តតួនាទី ភារកិច្ច និង (៤)យល់ដឹងអំពីសារៈសំខាន់នៃការកសាងបណ្តាញក្រុមប្រឹក្សាជាស្ត្រី។ ជាលទ្ធផលអ្នកចូលរួមមានការពេញចិត្តនឹងសិក្ខាសាលាទាំង៣ ដែលបានផ្តល់ដោយសារប្រធានបទទាំងអស់ឆ្លើយតបនឹងតម្រូវការរបស់ក្រុមប្រឹក្សាក្នុងការបំពេញតួនាទី ភារកិច្ចរបស់ពួកគាត់ ជាពិសេសពួកគាត់បានរៀនសូត្រច្រើនតាមរយៈការអនុវត្តផ្ទាល់ ដូចជា ការនិយាយជាសាធារណៈ ការស្វែងរកមតិគាំទ្រ ការសម្របសម្រួលកិច្ចប្រជុំ ជាពិសេស កិច្ចប្រជុំដែលមានការខ្វែងគំនិតគ្នា និងការរៀបចំសំណើគម្រោង។ ជាងនេះទៅទៀត តាមរយៈការរៀនសូត្រពីទ្រឹស្តីផ្សាភ្ជាប់នឹងការអនុវត្ត និងការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកក្នុងចំណោមបណ្តាញក្រុមប្រឹក្សាស្ត្រីទូទាំងប្រទេស បានជម្រុញឱ្យពួកគាត់កាន់តែមានទំនុកចិត្តលើខ្លួនឯង ក្នុងការបំពេញការងារ ដែលលទ្ធផលនេះបានគូសបញ្ជាក់បន្ថែមទៀតនូវក្នុងសិក្ខាសាលាឆ្លុះ

បញ្ចាំងប្រចាំឆ្នាំ ដើម្បីពង្រឹងបណ្តាញក្រុមប្រឹក្សាជាស្ត្រី ដែលបានរៀបចំ កាលពីថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងមកនេះ។ (របាយការណ៍សិក្ខាសាលាលំអិតមានភ្ជាប់ក្នុងឧបសម្ព័ន្ធ)

២. **រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់វគ្គកាតព្វកិច្ចដល់ថ្នាក់ដឹកនាំជាបុរស ស្ត្រីនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ទាក់ទងនឹងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម៖** ក្រោមការរៀបចំដោយក្រសួងកិច្ចការនារី ក្រុមការងារនៃលេខាធិការដ្ឋានគ.ជ.អ.ប បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលគ្រូបង្គោលនូវទូទាំង២៥ រាជធានី ខេត្ត ដែលមានសមាសភាពចូលរួមជាប្រធានមន្ទីរកិច្ចការនារី និងមន្ត្រីបច្ចេកទេស ទីប្រឹក្សាកម្មវិធីជាតិ មន្ត្រីមណ្ឌលអភិវឌ្ឍធនធានមនុស្ស សរុបចំនួន១២៥រូប (ស្រី ៧៥រូប)។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ដើម្បីបង្កើនសមត្ថភាពគ្រូបង្គោលនៅថ្នាក់ខេត្ត សម្រាប់យកទៅប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ និងដើម្បីបណ្តុះបណ្តាលបន្តទៀតដល់ថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិលើការងារការលើកកម្ពស់សមធម៌ និងបរិយាប័ន្នសង្គមនៅថ្នាក់ក្រោមជាតិ។ ជាលទ្ធផលគ្រូបង្គោលបានរៀបចំវគ្គបន្តអំពីការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នដល់គណៈអភិបាល ក្រុមប្រឹក្សា និងមន្ត្រីជំនាញនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រោមការជួយគាំទ្របច្ចេកទេសពីក្រុមការងារយេនឌ័រ នៃ គ.ជ.អ.ប។

៣. **ផ្តល់វគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពអំពីការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នក្នុងការដំណើរការផ្ទេរមុខងារ៖** ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងចំនួន១៤ ជាក្រសួង ដែលត្រូវផ្ទេរមុខងារ សរុបចំនួន ៦១រូប ស្ត្រីចំនួន ២០រូប បានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពទាក់ទងនឹងការលើកកម្ពស់សមធម៌សង្គមនិងបរិយាប័ន្នក្នុងការដំណើរការផ្ទេរមុខងារ។ វគ្គបណ្តុះបណ្តាល បានផ្តោតលើការគោលគំនិតយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ការបញ្ជ្រាបយេនឌ័រ និងវិធានការក្នុងលើកកម្ពស់សមធម៌សង្គមនិងបរិយាប័ន្នក្នុងដំណើរការផ្ទេរមុខងារ។ អ្នកចូលរួមមកពីក្រសួងទាំង១៤ បានចែករំលែកព័ត៌មាន និងបទពិសោធន៍លើការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន ដែលបានអនុវត្តកន្លងមក និងបន្តការអនុវត្តក្នុងការងារ និងដំណើរការនៃការផ្ទេរមុខងារ។

<u>**អនុសាសន៍ទី១១**</u>

១. **រៀបចំឯកសារបច្ចេកទេសស្តីពីការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖** លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយក្រសួងកិច្ចការនារី បានរៀបចំឯកសារបច្ចេក-ទេសនេះ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង និងជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានមូលដ្ឋានក្នុងការចាត់វិធានលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន នៅក្នុងការរៀបចំគោលនយោបាយផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ឯកសារនេះ បានធ្វើការផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងបានផ្តល់វគ្គបណ្តុះបណ្តាល់ដល់រដ្ឋបាលថ្នាក់ជាតិមួយចំនួនហើយ។(ឯកសារមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)

២. **ការរៀបចំសវនកម្មយេនឌ័រលើកទី២៖** ក្រុមការងារយេនឌ័រសម្រាប់គាំទ្រការអនុវត្តផអ៣ ដំណាក់កាលទី២ បានរៀបចំសវនកម្មយេនឌ័រលើកទី២ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងការអនុវត្តពាក់កណ្តាលនៃផែនការអនុវត្ត៣ឆ្នាំ ដំណាក់កាលទី២។ ជាងនេះទៅទៀតលទ្ធផលដែលរកឃើញ និងអនុសាសន៍នៃសវនកម្មយេនឌ័រ និងក្លាយជា

ធាតុចូលសម្រាប់ការរៀបចំផែនការអនុវត្ត៣ឆ្នាំ ដំណាក់កាលទី៣ ក៏ដូចជាផែនការសកម្មភាព និងថវិកាជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ស្ថានភាពយេនឌ័រឱ្យមានប្រសើរឡើង។ របាយការណ៍នៃសវនកម្មយេនឌ័រស្ថិតក្នុងដំណើរការរៀបចំ។

៣. **ពង្រាងផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីមុខតួនាទីធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រុមការងារយេនឌ័របានរៀបចំពង្រាងស្ថានភាព និងជម្រើសក្នុងការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើការពិគ្រោះយោបល់ជាច្រើនលើកជាមួយថ្នាក់ដឹកនាំ និងអ្នកបច្ចេកទេសក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិលមួយចំនួនដើម្បីបានជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ឯកសារយុទ្ធសាស្ត្រនេះ នឹងរៀបចំដាក់ជូនថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងសម្រេចនៅឆ្នាំ២០១៧ខាងមុខនេះ។

៤. **ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន សមធម៌សង្គមទៅក្នុងផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦ ដល់ ២០១៨ និងការអនុវត្តផែនការ៖**កម្មវិធីគណនេយ្យភាពសង្គមក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេស ក្រុមដែលតំណាងឱ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក្នុងការចូលរួមពង្រឹង ការចាត់ចែងធនធាន ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គ្រប់សមាសភាគនីមួយៗ នៃផែនការអនុវត្ត បានធ្វើការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម ដើម្បីចូលរួមចំណែកផ្តល់នូវប្រយោជន៍នានានៃការផ្តល់សេវាកាន់តែមានលក្ខណៈតម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងសមធម៌។ (ឯកសារផែនការអនុវត្តគណនេយ្យភាពសង្គមមានភ្ជាប់ក្នុងឧបសម្ព័ន្ធ)

៥. **ការបញ្ជ្រាបយេនឌ័រទៅក្នុងសេចក្តីណែនាំបច្ចេកទេស ស្តីពីការកសាងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ដើម្បីធានាបាននូវការចូលរួមពីគ្រប់តំណាងក្រុមប្រជាពលរដ្ឋ ជាពិសេសក្រុមស្ត្រី ជនពិការ យុវជន និងជនជាតិដើមភាគតិច ក្នុងដំណើរការរៀបចំផែនការការទទួលបានសេវា និងការអភិវឌ្ឍន៍មូលដ្ឋានឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះ និងក្រុមបាត់បង់ឱកាស ក្រុមការងារលេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងកិច្ចការនារីបានបញ្ជ្រាបយេនឌ័រ សមធម៌សង្គម និងបរិយាប័ន្នទៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំផែនការនិងមានទិន្នន័យបំបែកតាមភេទផងដែរ។(ឯកសារសេចក្តីណែនាំបច្ចេកទេសនេះស្ថិតក្នុងពង្រាងនៅឡើយ)

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកជំទាវ** មេត្តាជ្រាបជារបាយការណ៍។
សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ជ. **ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**